គម្រោងកំណែទំរង់រដ្ឋបាល និងគ្រប់គ្រង	147,623,225	193,198,592	47,411
មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍	753,238,502	985,784,034	241,910
គម្រោងបរិស្ថាន និងអនាម័យ	864,135,949	1,130,918,586	277,526
បង្កើតមជ្ឈមណ្ឌលកាត់បន្ថយភាពក្រីក្រកម្ពុជា	2,657,218,042	3,477,574,653	853,393
សន្តិសុខស្បៀងសម្រាប់គ្រួសារជនបទ	1,727,551,784	2,260,894,741	554,821
ការអភិវឌ្ឍធនធានមនុស្ស	2,066,725,144	2,704,780,286	663,750
គម្រោងគាំទ្រដំណើរការសេវនកម្មផ្ទៃក្នុង	510,560,323	668,184,398	163,972
ការអប់រំផ្សព្វផ្សាយ	378,059,477	494,776,882	121,418
ផ្តល់មុខជំនាញមូលដ្ឋាន និងបង្កើតការងារ	295,246,449	386,397,184	94,821
គម្រោងឥណទានជនបទ	2,206,427,122	2,887,612,124	708,616
គម្រោងផ្គត់ផ្គង់ទឹកជនបទ	2,952,464,491	3,863,971,837	948,214
ការអភិវឌ្ឍសហគ្រាស និងជំនួញខ្នាតតូច	1,843,490,024	2,412,626,318	592,056
គម្រោងធារាសាស្ត្រខ្នាតតូច	2,429,662,242	3,179,766,092	780,311
ពង្រឹងសមត្ថភាពលើការអភិវឌ្ឍភូមិ	797,165,413	1,043,272,396	256,018
ការស្រាវជ្រាវ និងផ្តល់ព័ត៌មានទីផ្សារ ផលិតផលកសិកម្មសំខាន់ៗដល់កសិករ	31,684,985	41,467,015	10,176
គម្រោងអភិវឌ្ឍន៍ភូមិ	1,517,278,703	1,985,704,551	487,289
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	**32,377,013,651**	**42,372,692,135**	**10,398,207**
សាងសង់ភូមិកាគកុមារ អេស អូ អេស	8,857,393,472	11,591,915,510	2,844,642
សាងសង់ និងអភិវឌ្ឍន៍លំនៅដ្ឋានសហគមន៍ក្រីក្រនៅរាជធានីភ្នំពេញ	1,242,915,539	1,626,637,900	399,175
សាងសង់មណ្ឌលទទួលជនរងគ្រោះ ដោយសារការជួញដូរមនុស្ស	310,368,828	406,188,259	99,678
សាងសង់មជ្ឈមណ្ឌល[illegible]សុំចត និងទទួលជនរងគ្រោះដោយសារការជួញដូរមនុស្ស និងជនងាយរងគ្រោះ	472,394,319	618,235,494	151,714
សាងសង់[illegible]ការិយាល័យសង្គមកិច្ច ចំនួន ១៥០	738,116,123	965,992,959	237,053
សាងសង់មជ្ឈមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះដោយការជួញដូរមនុស្ស កោះរំដួល	301,007,355	393,936,641	96,672
សាងសង់មជ្ឈមណ្ឌលជាតិជនពិការ	3,218,186,295	4,211,729,302	1,033,553

បញ្ជាក់: (*) [illegible]លេខគត់

ការគ្រប់គ្រងឆ្នាំ ២០១១

តារាង "ខ២"

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា៖ រៀល

ក្រសួង-ស្ថាប័ន	ច្បាប់ហិរញ្ញវត្ថុ	ការអនុវត្តឆ្នាំ២០១១	
ឈ្មោះគម្រោង	ឆ្នាំ២០១១	គិតជារៀល(*)	ដុល្លារ
សាងសង់វិទ្យាស្ថានជាតិសង្គមកិច្ច	1,718,190,311	2,248,643,123	551,814
សាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ	753,238,502	985,784,034	241,910
កសាងភូមិអភិវឌ្ឍន៍អតីតយុទ្ធជន	3,811,559,646	4,988,293,398	1,224,121
កសាងភូមិ និងអភិវឌ្ឍន៍អតីតយុទ្ធជន	4,431,577,189	5,799,727,484	1,423,246
សាងសង់មណ្ឌលស្តារលទ្ធភាពពលកម្ម កាយសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ ខេត្តស្ទឹងត្រែង	1,564,806,180	2,047,905,073	502,553
សាងសង់មណ្ឌលយុវនីតិសម្បទា	413,345,029	540,956,057	132,750
សាងសង់មជ្ឈមណ្ឌលសង្គមកិច្ចរាជធានីភ្នំពេញ	303,887,809	397,706,370	97,597
និរន្តរភាពមជ្ឈមណ្ឌលស្តារលទ្ធភាពកាយសម្បទាទាំង ១២	4,240,027,054	5,549,040,530	1,361,728
ក្រសួងទេសចរណ៍	**738,116,123**	**965,992,959**	**237,053**
បង្កើតសហគមន៍អេកូទេសចរណ៍នៅតំបន់អង្គរ	206,672,514	270,478,029	66,375
បង្កើតផលិតផលទេសចរណ៍នៅភាគខាងលើទន្លេមេគង្គកម្ពុជា	531,443,608	695,514,931	170,679
ក្រសួងធនធានទឹក និងឧតុនិយម	**547,685,763,610**	**716,771,487,877**	**175,894,844**
គម្រោងការពារទឹកជំនន់ទន្លេកំពង់ត្របែក	33,794,916,720	44,228,341,048	10,853,581
អភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រកង្គតជំហាន ១	54,228,851,450	70,970,795,887	17,416,146
អភិវឌ្ឍន៍ធនធានទឹកក្នុងស្ទឹងក្រាំងពន្លៃ	32,311,483,342	42,286,930,808	10,377,161
អភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រកាតពាយ័ព្យ	14,762,322,454	19,319,859,184	4,741,070
ជួសជុលប្រព័ន្ធធារាសាស្ត្រអង្គរសោង	9,447,886,371	12,364,709,878	3,034,285
ស្តារហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព នៅបូព៌ា និងញ្ញសាន ជំហានទី១ នឹងទី២	8,857,393,472	11,591,915,510	2,844,642
ស្តារប្រព័ន្ធស្រោចស្រព និងប្រព័ន្ធដោះទឹក	2,087,608,429	2,732,110,818	670,457
កសិកម្មខ្នាតតូច និងគាំពារសង្គម	5,904,928,982	7,727,943,673	1,896,428
អភិវឌ្ឍន៍ធនធានទឹកស្ទឹងកែវ	49,177,976,831	64,360,576,750	15,794,007
គម្រោងអភិវឌ្ឍន៍ទំនប់ទឹកស្ទឹងពោធិសាត់ (ទំនប់ទី១ នឹងទំនប់ទី២)	35,311,475,310	46,213,103,167	11,340,639
អភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពស្ទឹងសែន	26,572,180,417	34,775,746,531	8,533,926
ជួសជុលអាងទឹកស្រែង	29,878,940,647	39,103,394,988	9,595,925
អភិវឌ្ឍន៍អាងទឹកស្ទឹងតាសាល	8,857,393,472	11,591,915,510	2,844,642
អភិវឌ្ឍន៍ធនធានទឹកស្ទឹងពោធិសាត់ នៅទំនប់ទី៣ នឹងទី៥	23,619,715,926	30,911,774,694	7,585,712
គម្រោងស្ថិរភាពនៃការស្រោចស្រពតំបន់បឹងទន្លេសាប	23,619,715,926	30,911,774,694	7,585,712
គម្រោងអភិវឌ្ឍន៍ធារាសាស្ត្រវៃកូ	29,524,644,908	38,639,718,367	9,482,139
កម្មវិធីអភិវឌ្ឍន៍វិស័យគ្រប់គ្រងធនធានទឹក	11,809,857,963	15,455,887,347	3,792,856
កម្មវិធីអភិវឌ្ឍន៍វិស័យគ្រប់គ្រងធនធានទឹក	5,904,928,982	7,727,943,673	1,896,428
ការគ្រប់គ្រងទឹក [illegible] ប្រព័ន្ធស្រោចស្រព កំពត តាកែវ និងតំពង់ធំ	5,904,928,982	7,727,943,673	1,896,428
ជួសជុល[illegible]ល្អម្ងទា[illegible]ហ៊ាំងជ្រៃ	5,904,928,982	7,727,943,673	1,896,428
ការគ្រប់គ្រងធនធានទឹក[illegible]ពីទន្លេមេគង្គ	8,857,393,472	11,591,915,510	2,844,642
អភិ[illegible]លប្បុរី	11,514,611,514	15,069,490,163	3,698,034

ការគ្រប់គ្រងឆ្នាំ ២០១១

តារាង "១២"

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា៖ រៀល

ក្រសួង-ស្ថាប័ន	ច្បាប់ហិរញ្ញវត្ថុ	ការអនុវត្តឆ្នាំ២០១១	
ឈ្មោះគម្រោង	ឆ្នាំ២០១១	គិតជារៀល(*)	ដុល្លារ
ជួសជុលប្រព័ន្ធធារាសាស្ត្របាយ័នកោ	2,952,464,491	3,863,971,837	948,214
ជួសជុលទំនប់អាងទឹកសាលាតាអន	11,809,857,963	15,455,887,347	3,792,856
ជួសជុលប្រព័ន្ធធារាសាស្ត្រតាកែវ	14,762,322,454	19,319,859,184	4,741,070
កសិកម្មខ្នាតតូច និងគាំពារសង្គម	12,990,843,760	17,001,476,082	4,172,141
អភិវឌ្ឍន៍ធនធានទឹកស្ទឹងស្មោង	23,619,715,926	30,911,774,694	7,585,712
អភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រស្ទឹងស្វាស្លាប	8,857,393,472	11,591,915,510	2,844,642
សាងសង់ស្ថានីយ៍បូមទឹកថ្មីចំនួន ២០ កន្លែង	1,180,985,796	1,545,588,735	379,286
គម្រោងការពារទឹកជំនន់ និងគ្រោះរាំងស្ងួត	11,809,857,963	15,455,887,347	3,792,856
រៀបចំប្រព័ន្ធស្រោចស្រពកំពីងពួយ	1,180,985,796	1,545,588,735	379,286
ជួសជុលអាងទឹកព្រៃនប់	1,476,232,245	1,931,985,918	474,107
ស្តារស្ទឹងតូច-ស្តារអាងទន្លេបាទី និងសាងសង់ប្រព័ន្ធធារាសាស្ត្រ	4,428,696,736	5,795,957,755	1,422,321
ស្តារប្រព័ន្ធធារាសាស្ត្រតូចៗ ២៣ខេត្ត	11,809,857,963	15,455,887,347	3,792,856
អភិវឌ្ឍន៍ការស្រោចស្រពអាងទឹកស្ទឹងស្លាគូ	2,952,464,491	3,863,971,837	948,214
អាជ្ញាធរប្រេងកាតជាតិកម្ពុជា	**2,214,348,368**	**2,897,978,878**	**711,160**
បង្កើតបណ្ណាល័យទិន្នន័យប្រេងកាត	2,214,348,368	2,897,978,878	711,160
គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា	**16,373,215,885**	**21,428,079,915**	**5,258,425**
កម្មវិធីគ្រប់គ្រងធនធានធម្មជាតិ	16,373,215,885	21,428,079,915	5,258,425
រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	**14,467,076,005**	**18,933,462,000**	**4,646,248**
ការកែលម្អអាកាសយានដ្ឋានក្រចេះ	4,428,696,736	5,795,957,755	1,422,321
ការកែលម្អអាកាសយានដ្ឋានស្ទឹងត្រែង	2,952,464,491	3,863,971,837	948,214
គម្រោងកែលម្អខេត្តព្រះវិហារ	2,952,464,491	3,863,971,837	948,214
គម្រោងស្តារអាកាសយានដ្ឋានមណ្ឌលគិរី	4,133,450,287	5,409,560,571	1,327,500

" អត្រាប្តូរប្រាក់ ៤ ០៧៥រៀល ក្នុង ១ ដុល្លារអាមេរិក"

ROYAUME DU CAMBODGE LE MINISTRE ROYAL

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/៤២៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**
លោកព្រះគ្រូធម្មិកោ **ផល សុផា**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

ទារប. ១៣០៣. ២២៦

លេខ: ២២១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ៣ ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/២៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រទានព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០៥ រូប បានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានា
រួមចំណែកក្នុងការអភិវឌ្ឍលើវិស័យព្រះពុទ្ធសាសនានិងសង្គមជាតិ នៅក្នុងវត្តជោតនារាម
និងក្នុងអន្តេវាសិកដ្ឋានវត្តជោតនារាម ស្ថិតក្នុងឃុំស្នំក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

នូវ

ក- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

- លោក **ជា សីហា**

ខ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា** :

១- លោក **ម៉ៅ សុធី**

២- លោក **ជា ភិរុណរ័ត្ន**

គ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១- លោកជំទាវ **ថោង សុជាតា ស្រ៊ុំ ចាមរុង្គ**

២- អ្នកស្រី **ឡៅ គឹមលាង**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៧រ.ស. ១៧០៣.២២៧

លេខ: ២២២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៣
អគ្គលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី

សយ សុខា

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៣១៣/២៧៥

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី
ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម លោក លោកស្រី ជាសប្បុរសជន ចំនួន ៦៣ រូប ដែលមានគុណបំណាច់
ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឯកឧត្តម អ៊ុំ សារិទ្ធ
២-ឯកឧត្តម នៅ មុនីរោត
៣-ឯកឧត្តម ទូច ឆាយ
៤-ឯកឧត្តម សេង ស៊ីទុត្ថា
៥-ឯកឧត្តម អ៊ិត ឆាសនា
៦-លោក ឃុន លាងម៉េង
៧-លោក ប្លង់ ឆ្លាម
៨-លោក យឹម ប៊ុណ្ណារ៉ែត
៩-លោក ហ៊ឹង ប៊ុនជា
១០-លោកស្រី សា កញ្ញារិទ្ធ
១១-លោក ភឹម រាទី
១២-លោក អ៊ុយ សំភារ
១៣-លោក ស៊ូ លីន
១៤-លោក ប្លង់ សុផល
១៥-លោក សួង ពៅ
១៦-លោក ប៉ុក ច័ន្ទសំបូរ
១៧-លោក ឆេង សារីម
១៨-លោក តែប ច៉ាន្ទី
១៩-លោក សិរិទ្ធិ សុផល
២០-លោក ឆូ មណី
២១-លោកស្រី ម៉ៅ ធីតា
២២-លោក ហុក ឆ៉ាន់ធីណា
២៣-លោក ខួន អ៊ុម
២៤-លោក ប្រាក់ សាខុធ
២៥-លោក ញ៉ែម ចន្ថា
២៦-លោកស្រី គិម សត្ថាធី
២៧-លោកស្រី ស៊ី ចណ្ណនី
២៨-លោក ឈឹម គាន
២៩-លោក យ៉ា សុខន
៣០-លោក ជា ម៉េត
៣១-លោក តែប បញ្ញា
៣២-លោក ឃុត សុភាង
៣៣-លោក ឃុន ដាវីស
៣៤-លោក ហូ បូរិន
៣៥-លោក ជា បូរិទ្ធ
៣៦-លោក លឹម សារឿន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ខ/គ្រឿងឥស្សរិយយស ព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :

-ឧត្តមសេនីយ៍ត្រី **ជោត ហួត**

គ/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **មហាសេនា** :

១-លោក **ខឹម ពេជ្រ** ៥-លោក **ខិន ពិដោរ**

២-លោក **ព្រហ្ម ចាសនា** ៦-លោក **គង បូផា**

៣-លោក **ឃឹម រមនី** ៧-លោក **អ៊ុម ផានី**

៤-លោក **អូន ផុន** ៨-លោកស្រី **នុយ សំផុន**

ឃ/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **ធិបឌិន្ទ** :

១-លោកស្រី **លីយ៉ា ផានី** ៤-លោកស្រី **សុខ លក្ខិណា**

២-លោកស្រី **ស៊ឹម សុភា** ៥-លោក **ហុង សំថាន់**

៣-លោក **មូ សុវណ្ណារ័ត្ន** ៦-លោក **ដន សារិន**

ង/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **សេនា** :

១-លោក **សេន សុធា** ៤-លោក **ហ៊ុន ឈុនហៀង**

២-លោក **ពិន យុន** ៥-លោក **ប៊ុច ប៊ុន**

៣-លោក **ជួន ធី** ៦-លោក **លី ប៊ុនថា**

ច/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **អស្សឫទ្ធិ** :

១-លោក **សូ ផានិត** ៤-លោក **ញ៉ាញ់ ហាន**

២-លោក **ហុក គីមចេង** ៥-លោក **គឹម ធន**

៣-លោក **ស៊ុន ស៊ីណាត** ៦-លោក **ឡេង រតនា**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៧រស.១៣០៣.២៧៥

លេខៈ ២៧៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ៣ ឆ្នាំ២០១៣

អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/៤៤៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងមន្ត្រីរាជការ ចំនួន ០២ រូប ជាទីប្រឹក្សាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **អៀម យាង** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

២- ឯកឧត្តម **ប្អូង ណាល់** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ចរល.១៣០៣.៤៤៩

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខៈ ៧៧ ៤ ច.ល
ដើម្បីចម្លងជូន
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិនា ឆ្នាំ២០១៣
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១៣/៤២៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងលោកជំទាវ **ឃ្លោក ម៉េងថុល** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា មានឋានៈស្មើ **អគ្គនាយក** ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

ពរល.០៣១៣.៤៣០

លេខ: ៤៦៣ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១[illegible] ខែ មីនា ឆ្នាំ២០១៣
អគ្គលេខា[illegible]រាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីសរុបទំហំ ៧៦១ ហិកតា នៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ក្នុងនោះកាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងកាត់ចេញពីដីព្រៃដែលមានដីកាដកហូត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២៨៣ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៣៧០ ខ.បជ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ **៧៦១ ហិកតា** ក្នុងនោះ (១)ទំហំ **២០៦,៩៦ ហិកតា** កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និង(២)ទំហំ **៥៥៤.០៤ ហិកតា** កាត់ចេញពីដីព្រៃដែលមានដីកាដកហូត (លេខ ១៩៦ ១៩៨ ២១៧ ខបជ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៦) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ **៦៩៩,៨៩ ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ **៦១,១១ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដែលក្នុងនោះរួមមាន ៖

- ផ្ទៃដីទំហំ **១១៧,៦៣ ហិកតា** កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ សម្រាប់ធ្វើប្រទានកម្មទំហំ **១១៤,០៣ ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង **៣,៦០ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ **នៅភូមិជោគជ័យ**
- កាត់ផ្ទៃដីសរុបទំហំ **២០៨,៧៨ ហិកតា** ក្នុងនោះ(១) ទំហំ **៨៩,៣៣ ហិកតា** កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និង(២)ទំហំ **១១៩,៤៥ ហិកតា** កាត់ចេញពីដីគម្របព្រៃដែលមានដីកាដកហូត សម្រាប់ធ្វើប្រទានកម្មទំហំ **១៧៩,១១ ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង **២៩,៦៧ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ **នៅភូមិព្រៃចាន់**

- ផ្ទៃដីទំហំ ២២០,៧៣ ហិកតា កាត់ចេញពីដីគម្របព្រៃដែលមានដីកាដកហូត សម្រាប់ធ្វើប្រទានកម្មទំហំ ២១១,៤០ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង ៩,៣៣ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ **នៅភូមិព្រាវ**
- ផ្ទៃដីទំហំ ១៦៥,៧៦ ហិកតា កាត់ចេញពីដីគម្របព្រៃដែលមានដីកាដកហូត សម្រាប់ធ្វើប្រទានកម្មទំហំ ១៥០,៤៣ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង ១៥,៣៣ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ **នៅភូមិសីលាខ្មែរ**
- ផ្ទៃដីទំហំ ៥៨,១០ ហិកតា កាត់ចេញពីដីគម្របព្រៃដែលមានដីកាដកហូត សម្រាប់ធ្វើប្រទានកម្មទំហំ ៥៤,៩២ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង ៣,១៨ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ **នៅភូមិទំនប់ដាច់**

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) (២) (៣) (៤) និង (៥)នៃអនុក្រឹត្យនេះ ។

មាត្រា ២..

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ២៨៣ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ក្នុងនោះរួមមាន ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **២៧ គ្រួសារ** នៅភូមិជោគជ័យ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **១៧៨ គ្រួសារ** នៅភូមិព្រៃចាន់
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **៣២ គ្រួសារ** នៅភូមិព្រាវ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **៣៤ គ្រួសារ** នៅភូមិសីលាខ្មែរ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **១២ គ្រួសារ** នៅភូមិទំនប់ដាច់ ។

មាត្រា ៣..

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំ ១.៨៧៥ ហិកតា នៅស្រុកមេមត់ ខេត្តកំពង់ចាម ចេញពីព្រៃសម្បទាន របស់ក្រុមហ៊ុន សាម លីញ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨៦៥ គ្រួសារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៨៧ លខ.កច ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ទំហំ **១.៨៧៥ ហិកតា** ចេញពីព្រៃសម្បទានរបស់ក្រុមហ៊ុន សាមលីញ (ទំហំ ១.៥០៨ ហិកតា នៅភូមិកំបាស់ និងទំហំ ៣៦៧ ហិកតា នៅភូមិទ្រៀក) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិកំបាស់ និងភូមិទ្រៀក ឃុំមេមង ស្រុកមេមត់ ខេត្តកំពង់ចាម តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨៦៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែង នៅភូមិកំបាស់ និងភូមិទ្រៀក ឃុំមេមង ស្រុកមេមត់ ខេត្តកំពង់ចាម។

មាត្រា ៣ .-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកដាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ៦ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១០៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣

សម្រេច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដែលហៅកាត់ថា អគ្គលេខាធិការដ្ឋាន គ.ជ.ន.ជ.។

ជំពូកទី២
តួនាទីនិងភារកិច្ច

មាត្រា ២.-

អគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.** មានតួនាទីជាសេនាធិការរបស់ **គ.ជ.ន.ជ.** និងមានភារកិច្ចដូចតទៅៈ

- គ្រប់គ្រងការងាររដ្ឋបាល ហិរញ្ញវត្ថុ និងបច្ចេកទេសរបស់ **គ.ជ.ន.ជ.**
- ជួយ **គ.ជ.ន.ជ.** ក្នុងការរៀបចំ គាំទ្របច្ចេកទេស និងសម្របសម្រួលការងាររៀបចំដែនដីនិងនគរូបនីយកម្ម នៅថ្នាក់ជាតិ នៅតាមតំបន់ និងនៅថ្នាក់ក្រោមជាតិ នៅព្រះរាជាណាចក្រកម្ពុជា
- ជួយ **គ.ជ.ន.ជ.** ក្នុងការដឹកនាំ ពិគ្រោះយោបល់ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ក្នុងការរៀបចំផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី
- ជួយ **គ.ជ.ន.ជ.** ក្នុងការណែនាំនិងសម្របសម្រួលការរៀបចំប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដីថ្នាក់រាជធានី និងផែនការរៀបចំដែនដីថ្នាក់ខេត្ត
- ជួយគាំទ្របច្ចេកទេស ក្នុងការរៀបចំគោលនយោបាយនិងក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងការរៀបចំដែនដី និងនគរូបនីយកម្ម
- រៀបចំសំណុំឯកសារជូន **គ.ជ.ន.ជ.** ដើម្បីសុំការយល់ព្រមពីរាជរដ្ឋាភិបាលលើសេចក្តីព្រាងផែនការរៀបចំដែនដីនៅថ្នាក់ជាតិ នៅតាមតំបន់ និងនៅថ្នាក់ខេត្ត និងប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី
- រៀបចំសំណុំឯកសារជូន **គ.ជ.ន.ជ.** ដើម្បីពិនិត្យនិងសម្រេចលើប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង និងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ
- ជួយ **គ.ជ.ន.ជ.** ក្នុងការតាមដាននិងវាយតម្លៃការអនុវត្តផែនការរៀបចំដែនដីនៅថ្នាក់ជាតិ នៅតាមតំបន់ និងនៅថ្នាក់ខេត្ត និងប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី ថ្នាក់ក្រុង ព្រមទាំងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ
- សិក្សាស្រាវជ្រាវ ប្រមូលផ្តុំ ចងក្រង និងរក្សាទុកឯកសារ ព័ត៌មាន
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ **គ.ជ.ន.ជ.**
- រៀបចំកិច្ចប្រជុំនានារបស់ **គ.ជ.ន.ជ.**
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូន **គ.ជ.ន.ជ.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែល **គ.ជ.ន.ជ.** ប្រគល់ជូន។

ជំពូកទី៣
រចនាសម្ព័ន្ធនិងការគ្រប់គ្រង

មាត្រា ៣.-

អគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។

មាត្រា ៤.-

អគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.** មានរចនាសម្ព័ន្ធដូចតទៅៈ

- ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ
- ផ្នែកផែនការរៀបចំដែនដីនៅថ្នាក់ជាតិ នៅតាមតំបន់ និងនៅថ្នាក់ខេត្ត
- ផ្នែកប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី
- ផ្នែកសមាហរណកម្មបច្ចេកទេស
- ផ្នែកនីតិកម្ម អប់រំ និងផ្សព្វផ្សាយ។

អគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.** អាចស្នើសុំពង្រីករចនាសម្ព័ន្ធថែមទៀតតាមការចាំបាច់។

អគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.** មានសិទ្ធិប្រើត្រាដោយឡែករបស់ខ្លួន ដែលបានទទួលការឯកភាពពីប្រធាន **គ.ជ.ន.ជ.**។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ៥.-

ផ្នែកនីមួយៗត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។ ប្រធានផ្នែកមានឋានៈស្មើនឹងប្រធាននាយកដ្ឋាន និងអនុប្រធានផ្នែកមានឋានៈស្មើនឹងអនុប្រធាននាយកដ្ឋាន។

ផ្នែកនីមួយៗ មានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះផ្នែក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលជាប្រធាន **គ.ជ.ន.ជ.**។

មាត្រា ៦.-

អគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.** មានមន្ត្រីបម្រើការមកពីក្របខ័ណ្ឌមុខងារសាធារណៈ។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.** អាចស្នើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាដើម្បីជួយបំពេញការងារ។

ជំពូកទី៤
តួនាទីនិងភារកិច្ចរបស់ផ្នែកនីមួយៗ

មាត្រា ៧.-

ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងការងាររដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន
- សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់អគ្គលេខាធិការដ្ឋាន ឲ្យមានភាពរលូននិងមានប្រសិទ្ធភាព
- រៀបចំកិច្ចប្រជុំ សិក្ខាសាលា និងពិធីការនានា
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.** ដើម្បីរៀបចំកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិលើការងាររៀបចំដែនដីនិងនគរូបនីយកម្ម ព្រមទាំងរិះរកវិធានការបង្កើនប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការនេះ
- ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់និងអន្តរជាតិ ដើម្បីបញ្ជូនមន្ត្រី បុគ្គលិកទៅធ្វើការសិក្សាដកពិសោធន៍ការងារពាក់ព័ន្ធនឹងការរៀបចំដែនដីនិងនគរូបនីយកម្ម
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ **គ.ជ.ន.ជ.**
- គ្រប់គ្រងថវិកានិងធ្វើរបាយការណ៍អំពីស្ថានភាពចំណូលចំណាយរបស់ **គ.ជ.ន.ជ.**
- ធ្វើលទ្ធកម្មក្នុងការផ្គត់ផ្គង់និងបែងចែកសម្ភារៈបរិក្ខារនិងធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់ **គ.ជ.ន.ជ.**
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ផ្នែកនិងរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.** ប្រគល់ជូន។

មាត្រា ៨.-

ផ្នែកផែនការរៀបចំដែនដីនៅថ្នាក់ជាតិ នៅតាមតំបន់ និងនៅថ្នាក់ខេត្ត មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងការរៀបចំផែនការរៀបចំដែនដីនៅថ្នាក់ជាតិ នៅតាមតំបន់ និងនៅថ្នាក់ខេត្ត

- ផ្តួចផ្តើមរៀបចំ គាំទ្របច្ចេកទេស និងសម្របសម្រួលក្នុងការរៀបចំផែនការរៀបចំដែនដីនៅថ្នាក់ជាតិ នៅតាមតំបន់ និងនៅថ្នាក់ខេត្ត
- សម្របសម្រួលសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ក្នុងការរៀបចំផែនការរៀបចំដែនដីនៅថ្នាក់ជាតិ នៅតាមតំបន់ និងនៅថ្នាក់ខេត្ត
- ចូលរួមរៀបចំសំណុំឯកសារ ដើម្បីស្នើសុំការយល់ព្រមពីរាជរដ្ឋាភិបាលលើសេចក្តីព្រាងផែនការរៀបចំដែនដីនៅថ្នាក់ជាតិ នៅតាមតំបន់ និងនៅថ្នាក់ខេត្ត
- សិក្សាស្រាវជ្រាវ ប្រមូលផ្តុំ ចងក្រង និងរក្សាទុកឯកសារ ព័ត៌មានផែនការរៀបចំដែនដីនៅថ្នាក់ជាតិ នៅតាមតំបន់ និងនៅថ្នាក់ខេត្ត
- សិក្សានិងរៀបចំផែនការប្រើប្រាស់ដីសម្រាប់លំនៅឋាន
- ផ្តល់បច្ចេកទេសលើផ្នែកផែនការរៀបចំដែនដីនៅថ្នាក់ជាតិ នៅតាមតំបន់ និងនៅថ្នាក់ខេត្ត
- តាមដាននិងវាយតម្លៃការអនុវត្តផែនការរៀបចំដែនដីនៅថ្នាក់ជាតិ នៅតាមតំបន់ និងនៅថ្នាក់ខេត្ត
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ផ្នែក
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.** ប្រគល់ជូន។

មាត្រា ៩.-

ផ្នែកប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី ក្រុង និងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ
- ផ្តួចផ្តើមរៀបចំ គាំទ្របច្ចេកទេស និងសម្របសម្រួលក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី ក្រុង និងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ
- សម្របសម្រួលសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី ក្រុង និងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ
- ចូលរួមរៀបចំសំណុំឯកសារជូន **គ.ជ.ន.ជ.** ដើម្បីពិនិត្យនិងសម្រេចលើសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង និងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ ព្រមទាំងដើម្បីស្នើសុំការយល់ព្រមពីរាជរដ្ឋាភិបាល លើសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី
- សិក្សាស្រាវជ្រាវ ប្រមូលផ្តុំ ចងក្រង និងរក្សាទុកឯកសារ ព័ត៌មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី ក្រុង និងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ
- សិក្សានិងរៀបចំផែនការប្រើប្រាស់ដីសម្រាប់លំនៅឋានរាជធានី ក្រុង ស្រុក ខណ្ឌ
- ផ្តល់បច្ចេកទេសលើផ្នែកប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី
- តាមដាននិងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ផ្នែក
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.** ប្រគល់ជូន។

មាត្រា ១០.-

ផ្នែកសមាហរណកម្មបច្ចេកទេស មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវនិងចូលរួមរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស សេវាកម្ម សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងវប្បធម៌

- សិក្សានិងរៀបចំសេចក្តីព្រាងលើការធ្វើសមាហរណកម្មនិងតម្រូវការហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស សេវាកម្ម សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងវប្បធម៌ ក្នុងផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីឲ្យមានប្រសិទ្ធភាពនិងមាននិរន្តរភាព
- រៀបចំសំណុំឯកសារជូន **គ.ជ.ន.ជ.** ដើម្បីពិនិត្យនិងសម្រេចលើសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង និងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ ព្រមទាំងធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការអនុម័តផែនការនិងប្លង់ខាងលើនេះ
- រៀបចំសំណុំឯកសារជូន **គ.ជ.ន.ជ.** ដើម្បីស្នើសុំការយល់ព្រមពីរាជរដ្ឋាភិបាលលើសេចក្តីព្រាងផែនការរៀបចំដែនដីនៅថ្នាក់ជាតិ នៅតាមតំបន់ និងនៅថ្នាក់ខេត្ត ព្រមទាំងប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី
- ចូលរួមរៀបចំ គាំទ្របច្ចេកទេស និងសម្របសម្រួលក្នុងការកសាងផែនការរៀបចំដែនដីនៅថ្នាក់ជាតិនិងនៅតាមតំបន់ និងនៅថ្នាក់ក្រោមជាតិ ដោយផ្តោតលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស សេវាកម្ម សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងវប្បធម៌
- ផ្តល់បច្ចេកទេសលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស សេវាកម្ម សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងវប្បធម៌
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ផ្នែក
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.** ប្រគល់ជូន។

មាត្រា ១១.-

ផ្នែកនីតិកម្ម អប់រំ និងផ្សព្វផ្សាយ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សិក្សា ស្រាវជ្រាវ រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ចាំបាច់នានាពាក់ព័ន្ធនឹងការរៀបចំដែនដីនិងនគរូបនីយកម្ម ដើម្បីដាក់ជូន **គ.ជ.ន.ជ.** ពិនិត្យនិងសម្រេច
- អប់រំនិងបណ្តុះបណ្តាលធនធានមនុស្ស ដែលពាក់ព័ន្ធនឹងការរៀបចំដែនដីនិងនគរូបនីយកម្ម ដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិនិងភាគីពាក់ព័ន្ធ
- ចងក្រង បោះពុម្ព និងផ្សព្វផ្សាយគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសនានាដែលពាក់ព័ន្ធការរៀបចំដែនដីនិងនគរូបនីយកម្មដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិនិងភាគីពាក់ព័ន្ធ
- ផ្សព្វផ្សាយព័ត៌មានស្តីពីការរីកចម្រើននៃការងាររៀបចំដែនដីនិងនគរូបនីយកម្ម តាមរយៈការធ្វើសិក្ខាសាលា តុមូល សន្និសីទសារព័ត៌មាន។ល។
- រៀបចំបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.**
- ទទួលបណ្តឹងតវ៉ា ធ្វើការស៊ើបអង្កេត សម្របសម្រួល និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងបណ្តឹងតវ៉ាទាំងនោះ
- សិក្សានិងឲ្យមតិលើកិច្ចព្រមព្រៀងនិងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការរៀបចំដែនដីនិងនគរូបនីយកម្ម
- តាមដាននិងវាយតម្លៃលើសកម្មភាពការងារនីតិកម្ម អប់រំ និងផ្សព្វផ្សាយ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ផ្នែក
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន **គ.ជ.ន.ជ.** ប្រគល់ជូន។

ជំពូកទី៥
អវសានប្បញ្ញត្តិ

មាត្រា ១២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ១៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធាន **គ.ជ.ន.ជ.** រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ មិនា ឆ្នាំ២០១៣
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន
នៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ន.ជ.



គំរូត្រារបស់អគ្គលេខាធិការដ្ឋាន គ.ជ.ន.ជ.



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៧៩៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសការងារ ជូនលោក សន វិចិត្រ ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧៨៧-អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសការងារ ជូនលោក អ៊ុំ សុខុន ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៧៦៧.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសការងារ ជូនកញ្ញា ចាន់ សម្បត្តិ ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ ៨ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៧៥៥ . អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសការងារ ជូនកញ្ញា **សយ ស្រីមុំ** ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៩០០ . អនក្រ . បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសការងារ ជូនលោក សំអឿន សោភារម្យ ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ។

មាត្រា ២.-

